គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា
ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ
16 Street 99, Phnom Penh - www.ngocedaw.org – ngocedaw.pnh@gmail.com

ADHOC
AFD
AFESIP
AHRDHE
AMARA
BSO
BWAP
CADEA
CADPP
CAMBOW
CARAM
CAREPO
CCIM
CCPCR
CD Cam
CDP
CDPO
CDRC
CDRCP
CFSWF
CODO
COSECAM
CRD
CSC
CSD
CWCC
CWDA
CWPD
DAC
EOCS
EDCO
FAA
FLO
FLOW
GAD/C
GGAC
IDA
KHEMARA
KIFHRDA
KKKHRA
KWCD
KWVC
KYA
LAC
LICADHO
MEC
ML&NV
NAPA
NEP
NGO Forum
NICFEC
OGB
OI
PCC
PYD
RAA
RHB
RHAC
SABORAS
SERRC
SILAKA
SK
USG
VAWCC
VIGILANCE
VYCD
WDA
WFP
WLA
WMC
WODAC
WOSO
YRDP

# សារលិខិត
## រំលែកព្រះរាជបរមទុក្ខ របស់

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា
ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ
The Cambodian NGO Committee on CEDAW (NGO-CEDAW)

សូមក្រាបបង្គំទូលថ្វាយព្រះបាទសម្តេចបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ខ្ញុំម្ចាស់ ទូលព្រះបង្គំជាថ្នាក់ដឹកនាំ និងសមាជិករបស់គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ មានសេចក្តីក្តុកក្តួលក្នុងចិត្តឥតឧបមា ដោយបានទទួលដំណឹងដ៏សែនក្រៀមក្រំជាទីបំផុត ដែល**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ព្រះអង្គបានសោយទីវង្គតនៅថ្ងៃទី១៥រោជ ខែភទ្របទ ឆ្នាំរោង ចត្វាស័ក ពស២៥៥៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង១:២០នាទីរំលង អាធ្រាត (ម៉ោងនៅរាជធានីភ្នំពេញ) ក្នុងព្រះជន្មាយុ ៩០ព្រះវស្សា ដោយព្រះជរាពាធ នៅទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន ។

ការសោយទីវង្គតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** គឺជាការបាត់បង់នូវអគ្គមហាបុរសរដ្ឋមួយអង្គដ៏សែនឆ្នើមបំផុត និងប្រកបដោយទឹកព្រះទ័យដ៏អង់អាចក្លាហានក្រៃលែង ដែលព្រះអង្គទ្រង់បានធ្វើព្រះរាជបូជនីយកិច្ច ក្នុងការទាមទារយកមកបាននូវឯករាជ្យជាតិ បូរណភាពទឹកដី និងការអភិវឌ្ឍប្រកបដោយសន្តិភាពលើគ្រប់វិស័យ ជូនជាតិមាតុភូមិ ដែលជាមោទនភាពរបស់ជាតិមាតុភូមិ និងប្រជានុរាស្ត្ររបស់ព្រះអង្គ ហើយដែលត្រូវបានសាធារណៈមតិជាតិ និងអន្តរជាតិកោតសរសើរគោរពស្ញប់ស្ញែងក្រៃលែង ហើយថ្វាយព្រះរាជគោរម្យងារជាសម្តេចអគ្គមហារដ្ឋ ដែលជាអគ្គមគ្គុទេសដ៏ឆ្នើម ។

ក្នុងឱកាសដ៏សែនក្រៀមក្រំបំផុតនេះ ខ្ញុំម្ចាស់ ទូលព្រះបង្គំជាថ្នាក់ដឹកនាំ និងសមាជិករបស់គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ សូមសម្តែងនូវការសោកស្តាយ និងចូលរួមរំលែកទុក្ខព្រួយដ៏ធ្ងន់ធ្ងរបំផុតនេះ ជាមួយសម្តេចព្រះមហាក្សត្រិយ៍ **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និងព្រះរាជវង្សានុវង្សទាំងអស់ ហើយសូមព្រះបរមរាជានុញ្ញាតលំអោនកាយឧទ្ទិសបួងសួងដល់វិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** សូមព្រះអង្គទ្រង់យាងសោយសុខក្នុងព្រះបរមសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសម្តេចព្រះមហាក្សត្រិយ៍ ព្រះវររាជមាតាជាតិខ្មែរ ព្រះមេត្តាទទួលនូវគារវភក្តីដ៏ស្មោះស្ម័គ្របំផុតអំពីខ្ញុំម្ចាស់ និងទូលបង្គំទាំងអស់គ្នា ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២

ហត្ថលេខា និងត្រា

លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវកេក

ប្រធាន និងតំណាងអោយសមាជិកទាំងអស់របស់គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ